ខិតប័ណ្ណព័ត៌មាន

Khmer | ភាសាខ្មែរ

# ពានរង្វាន់ពលរដ្ឋវិចថូរៀវ័យចំណាស់ប្រចាំឆ្នាំ 2024

## តែងតាំងមនុស្សវ័យចំណាស់ម្នាក់សម្រាប់ពានរង្វាន់ពលរដ្ឋវិចថូរៀវ័យចំណាស់ប្រចាំឆ្នាំ

តែងតាំងពលរដ្ឋវិចថូរៀវ័យចំណាស់ម្នាក់ ដែលចែករំលែកជំនាញ បទពិសោធន៍ ពេលវេលា និងថាមពលរបស់ពួកគេ ដើម្បីជួយអ្នកដទៃនៅក្នុងសហគមន៍។

**ការតែងតាំងគឺបើកទទួលរហូតដល់ថ្ងៃអាទិត្យ ទី 11 ខែសីហា ឆ្នាំ 2024។**

ដើម្បីមានសិទ្ធិទទួលបានពានរង្វាន់នេះ បុគ្គលម្នាក់ត្រូវតែ៖

- ជាពលរដ្ឋអូស្ត្រាលី
- រស់នៅក្នុងរដ្ឋវិចថូរៀ
- អាយុ 60 ឆ្នាំ ឬអាយុលើសនេះ។
- ពលរដ្ឋវិចថូរៀដែលជាជនជាតិដើម Aboriginal និងអ្នកកោះ Torres Strait មានអាយុ 50 ឆ្នាំ ឬអាយុលើសនេះ។

បុគ្គលម្នាក់មិនមានសិទ្ធិទេ ប្រសិនបើពួកគេ៖

- ធ្លាប់ឈ្នះពានរង្វាន់ពលរដ្ឋវិចថូរៀវ័យចំណាស់ប្រចាំឆ្នាំកាលពីមុនមក
- តែងតាំងខ្លួនឯង។

ការតែងតាំងត្រូវតែធ្វើឡើងជាភាសាអង់គ្លេស។ ប្រសិនបើអ្នកត្រូវការជំនួយក្នុងការបំពេញទម្រង់បែបបទតាមអនឡាញ សូមសួរសមាជិកគ្រួសារ មិត្តភ័ក្តិ ឬអង្គការសហគមន៍ដើម្បីជួយអ្នក។

### សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS)

Interpreter

អ្នកអាចហៅទូរសព្ទទៅសេវាបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់នៅពេលណាក៏បានក្នុងអំឡុងពេលថ្ងៃ ជារៀងរាល់ថ្ងៃនៃឆ្នាំ។ អ្នកនឹងត្រូវនិយាយភាសាដែលអ្នកត្រូវការ នៅពេលប្រតិបត្តិករទូរសព្ទសួរ។

ទូរសព្ទ៖ 131 450 (នៅក្នុងប្រទេសអូស្ត្រាលី)
ទូរសព្ទ៖ +613 9268 8332 (នៅក្រៅប្រទេសអូស្ត្រាលី)

ប្រសិនបើអ្នកត្រូវការជំនួយ ឬទម្រង់បែបបតែងតាំងជាក្រដាសស្នាម សូមទាក់ទងក្រុមការងាររៀបចំពិធីសម្រាប់មនុស្សវ័យចំណាស់ តាមរយៈលេខ (03) 8850 6164 ឬអ៊ីមែល <seniorsfestival@dffh.vic.gov.au>

ដើម្បីទទួលបានឯកសារនេះជាទម្រង់មួយផ្សេងទៀត សូមហៅទូរសព្ទទៅលេខ (03) 8850 6164 ដោយប្រើសេវាកម្មជាតិផ្នែកប្រាស្រ័យទាក់ទងជាមួយជនពិការ (National Relay Service) តាមលេខ 13 36 77 ប្រសិនបើត្រូវការ ឬ អ៊ីមែល ក្រុមការងាររៀបចំពិធីសម្រាប់មនុស្សចាស់នៅលើគេហទំព័រ <seniorsfestival@dffh.vic.gov.au>

បានអនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋាភិបាលរដ្ឋវិចថូរៀ (Victorian Government), 1 Treasury Place, Melbourne។

© រដ្ឋវិចថូរៀ ប្រទេសអូស្ត្រាលី ក្រសួងទទួលបន្ទុកគ្រួសារ យុត្តិធម៌ និងផ្ទះសម្បែង ខែមិថុនា ឆ្នាំ 2024។

នៅក្នុងឯកសារនេះ 'Aboriginal' សំដៅលើទាំងជនជាតិដើម និងអ្នកកោះ Torres Strait។ 'Indigenous' ឬ 'Kori/Koorie' ត្រូវបានរក្សាទុកជាមួយផ្នែកនៃចំណងជើងនៃរបាយការណ៍ កម្មវិធី ឬសម្រង់ណាមួយ។

COTA VICTORIA

Victorian Seniors Festival

VICTORIA State Government

# ប្រភេទ និងលក្ខណៈវិនិច្ឆ័យនៃពានរង្វាន់

អ្នកអាចតែងតាំងបុគ្គលម្នាក់ក្នុងប្រភេទពានរង្វាន់ខាងក្រោមនេះ៖

| ប្រភេទនៃរង្វាន់ | លក្ខណៈវិនិច្ឆ័យនៃរង្វាន់ |
|---|---|
| **ពានរង្វាន់របស់រដ្ឋមន្ត្រីសម្រាប់ពលរដ្ឋវិចថូរៀវ័យចំណាស់ប្រចាំឆ្នាំ (Premier's Award for Victorian Senior of the Year)** សម្រាប់ការរួមចំណែកដ៏ឆ្នើមរបស់បុគ្គលម្នាក់ចំពោះសហគមន៍មូលដ្ឋានរបស់ពួកគេ និង រដ្ឋវិថូរៀ។ | អ្នកដែលត្រូវតែងតាំងរបស់អ្នក៖<br>• បានចូលរួមចំណែកដ៏ឆ្នើមដល់សហគមន៍មូលដ្ឋានរបស់ពួកគេ និងរដ្ឋវិថូរៀ<br>• បង្កើតភាពខុសប្លែកមួយដល់សុខុមាលភាពសហគមន៍តាមរយៈការស្ម័គ្រចិត្ត<br>• ត្រូវបានគោរពដោយសហគមន៍<br>• មានអាកប្បកិរិយាវិជ្ជមានចំពោះភាពចាស់ដែលបំផុសគំនិតដលអ្នកដទៃ<br>• បង្កើតអត្ថប្រយោជន៍យូរអង្វែងជាមួយនឹងសកម្មភាពនានារបស់ពួកគេ |
| **លើកកម្ពស់ពានរង្វាន់ពហុវប្បធម៌ (Multiculturalism Award)** ដល់បុគ្គលម្នាក់ចំពោះការរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់អត្ថប្រយោជន៍នៃភាពចម្រុះផ្នែកវប្បធម៌នៅក្នុងសហគមន៍មូលដ្ឋានរបស់ពួកគេ ឬនៅក្នុងសហគមន៍ទូលំទូលាយ។ | អ្នកដែលត្រូវតែងតាំងរបស់អ្នក៖<br>• លើកកម្ពស់អត្ថប្រយោជន៍នៃភាពចម្រុះផ្នែកវប្បធម៌នៅក្នុងសហគមន៍<br>• បំផុសគំនិត ឬបង្កើតភាពខុសប្លែកមួយដល់សុខុមាលភាពសហគមន៍តាមរយៈការស្ម័គ្រចិត្ត<br>• មានអាកប្បកិរិយាវិជ្ជមានចំពោះភាពចាស់ដែលបំផុសគំនិតដល់អ្នកដទៃ។ |
| **ពានរង្វាន់ការរស់នៅប្រកបដោយសុខភាព និងសកម្ម (Healthy and Active Living Award)** ដល់បុគ្គលម្នាក់សម្រាប់ការជួយបង្កើតសហគមន៍ដែលសកម្ម និងមានសុខភាពល្អតាមរយៈការចូលរួមជាមួយសហគមន៍ និងតួនាទីជាគំរូ។ | អ្នកដែលត្រូវតែងតាំងរបស់អ្នក៖<br>• ជួយបង្កើតសហគមន៍មួយដែលសកម្ម និងមានសុខភាពល្អ<br>• បង្កើត ឬដំណើរការគំនិតផ្តួចផ្តើមនៅក្នុងសហគមន៍ ដើម្បីលើកទឹកចិត្តអ្នកដទៃឱ្យកាន់តែមានសុខភាពល្អ និងសកម្ម<br>• ធ្វើឱ្យមានភាពខុសប្លែកមួយដល់សុខុមាលភាពសហគមន៍តាមរយៈការស្ម័គ្រចិត្ត<br>• មានអាកប្បកិរិយាវិជ្ជមានចំពោះភាពចាស់ដែលបំផុសគំនិតដល់អ្នកដទៃ។ |
| **ពានរង្វាន់សហគមន៍អតីតយុទ្ធជន (Veteran Community Award)** ដល់មនុស្សម្នាក់សម្រាប់ការរួមចំណែកដ៏អស្ចារ្យដល់សហគមន៍អតីតយុទ្ធជន។ បុគ្គលនោះមិនចាំបាច់ជាអតីតយុទ្ធជនទេ។ | អ្នកដែលត្រូវតែងតាំងរបស់អ្នក៖<br>• បានចូលរួមចំណែកដ៏អស្ចារ្យដល់សហគមន៍អតីតយុទ្ធជន<br>• បំផុសគំនិត ឬបង្កើតភាពខុសប្លែកមួយដល់សុខុមាលភាពសហគមន៍តាមរយៈការស្ម័គ្រចិត្ត<br>• សម្រេចបាន ឬបង្កើតអត្ថប្រយោជន៍សម្រាប់សហគមន៍ទូលំទូលាយ<br>• មានអាកប្បកិរិយាវិជ្ជមានចំពោះភាពចាស់ដែលបំផុសគំនិតដល់អ្នកដទៃ។ |
| **ពានរង្វាន់ការមានសុខភាពល្អក្នុងភាពវ័យចាស់ (Aging Well Award)** ដល់បុគ្គលដែលធ្វើការដើម្បីប្រយុទ្ធប្រឆាំងនឹងភាពចាស់និយម លើកកម្ពស់យុត្តិធម៌សង្គម និងចូលរួមជាមួយសហគមន៍ដើម្បីគាំទ្រគំនិតផ្តួចផ្តើមមានសុខភាពល្អក្នុងភាពវ័យចាស់។ | អ្នកដែលត្រូវតែងតាំងរបស់អ្នក៖<br>• ធ្វើការដើម្បីប្រយុទ្ធប្រឆាំងនឹងភាពចាស់និយមនៅក្នុងសហគមន៍<br>• លើកកម្ពស់យុត្តិធម៌សង្គម<br>• ចូលរួមជាមួយសហគមន៍ដើម្បីគាំទ្រគំនិតផ្តួចផ្តើមមានសុខភាពល្អក្នុងភាពវ័យចាស់<br>• បំផុសគំនិត ឬបង្កើតភាពខុសមួយដល់សុខុមាលភាពសហគមន៍តាមរយៈការស្ម័គ្រចិត្ត។ |
| **ពានរង្វាន់ COTA (Council on the Ageing) ពានរង្វាន់អ្នកសម្រេចជោគជ័យពលរដ្ឋវិចថូរៀវ័យចំណាស់ Victoria (Victoria Senior Achiever Awards)** ចំពោះការរួមចំណែកយ៉ាងសំខាន់ដល់សហគមន៍មូលដ្ឋាន និងរដ្ឋវិថូរៀ។ | អ្នកដែលត្រូវតែងតាំងរបស់អ្នក៖<br>• បានរួមចំណែកយ៉ាងធំធេងដល់សហគមន៍មូលដ្ឋាននានា និងរដ្ឋវិចថូរៀ<br>• បំផុសគំនិត ឬបង្កើតភាពខុសមួយដល់សុខុមាលភាពសហគមន៍តាមរយៈការស្ម័គ្រចិត្ត។ |

សម្រាប់ព័ត៌មានបន្ថែមអំពីពានរង្វាន់ពលរដ្ឋវិចថូរៀវ័យចំណាស់ប្រចាំឆ្នាំ ឬធ្វើការតែងតាំង សូមចូលមើល Seniors Online <https://www.seniorsonline.vic.gov.au/awards>